


# សេចក្តីប្រកាសព័ត៌មាន

## "ស្ត្រីកម្ពុជាឆ្ពោះទៅរកភាពរីកចម្រើន"

## ថ្ងៃទី ០៦_០៨ ខែកញ្ញា ឆ្នាំ២០១១

## នៅសណ្ឋាគារ អ៊ីនធើកុងទីណង់តាល់ រាជធានី ភ្នំពេញ

យើងខ្ញុំគណៈកម្មការរៀបចំ **សន្និសីទស្ត្រីនៅកម្ពុជា** ដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិលមានកិត្តិយសជំរាបថា នៅថ្ងៃទី ០៦-០៨ ខែកញ្ញា ឆ្នាំ២០១១ នៅសណ្ឋាគារ អ៊ីនធើកុងទីណង់តាល់ នឹងមានការរៀបចំសន្និសីទស្តីពីស្ត្រីនៅកម្ពុជា ក្រោមប្រធានបទ "**ស្ត្រីកម្ពុជា ឆ្ពោះទៅរកភាពរីកចម្រើន**"។ អង្គពិធីនេះត្រូវបានគ្រោងរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**។

**សន្និសីទនេះ** នឹងចាប់ផ្តើមនៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១១ នៅសណ្ឋាគារ អ៊ីនធើកុងទីណង់តាល់ វេលាម៉ោង ៨ព្រឹក។ វាគ្មិនសំខាន់ៗដែលអញ្ជើញមកពីអង្គការជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចដែលមានជំនាញលើប្រធានបទចំបងៗរួមមាន:

១. តុល្យភាពរវាងទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងសិទ្ធិស្ត្រី

២. ការទទួលបានការអប់រំ និងស្ត្រីក្នុងភាពជាអ្នកដឹកនាំ

៣. អំពើហិង្សាលើស្ត្រី យុត្តិធម៌ស្ត្រី និងសុខភាពស្ត្រី

៤. យុត្តិធម៌ខាងផ្នែកសេដ្ឋកិច្ចចំពោះស្ត្រី

៥. ការពង្រឹងយន្តការការងាររវាងអង្គការសង្គមស៊ីវិល និងអង្គការសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាល រួមជាមួយវិស័យឯកជនដើម្បីដោះស្រាយបញ្ហាយេឌ័រ និងជំហានបន្ទាប់

៦. ការផ្តល់ជំនួយ ដែលមានប្រសិទ្ធភាពដើម្បីលើកកំពស់សិទ្ធិស្ត្រី ។

***សន្និសីទស្តីពីស្ត្រីនៅកម្ពុជា*** រៀបចំឡើងក្នុងគោលបំណងបង្កើតឱ្យមាននូវក្របខណ្ឌការងារជារួមមួយ ដើម្បីជម្រុញឱ្យស្ថានភាពស្ត្រីនៅកម្ពុជាមានភាពកាន់តែប្រសើរឡើង ទាំងក្នុងឆាកនយោបាយ សង្គម និងសេដ្ឋកិច្ច ដែលជាកត្តាដ៏សំខាន់ក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះដែរ នឹងមានការអញ្ជើញចូលរួមពីអង្គការសង្គមស៊ីវិល ស្ថាប័នជាតិ និងក្រោមជាតិ សមាគមមូលដ្ឋានតំណាងស្ត្រីងាយរងគ្រោះ ស្ត្រីជាសមាជិកានៃក្រុមប្រឹក្សាឃុំ ដៃគូអភិវឌ្ឍន៍នានា ប្រចាំប្រទេសកម្ពុជាសរុប ចំនួនជាង ៤៩១ នាក់។


សម្រាប់ព័ត៌មានលំអិតសូមមេត្តាទាក់ទង

១-លោកស្រី **ចាន់ គន្ធា** មន្ត្រីសម្របសម្រួលកម្មវិធី

ទូរស័ព្ទលេខ **០១២ ៨៥៤ ២៩៥**

២-លោក **ស៊ិន ហុង** មន្ត្រីទំនាក់ទំនង

ទូរសព្ទ័លេខ **០១២ ៣២២ ០១២**

គេហទំព័រ: www.cpwp.silaka.org

អ៊ីម៉ែល: ncwc2011@silaka.org